**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សូមព្រះតេជៈគុណលើត្បូង**

**សូមក្រាបបង្គំទូលថ្វាយ ព្រះករុណា ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**

**ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ**

**ព្រះករុណាថ្លៃវិសេស !**

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃពិធីចំរើនព្រះជន្មវស្សានៃព្រះករុណាថ្លៃវិសេសជាអម្ចាស់ជីវិតតម្កល់លើត្បូង **ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** គម្រប់ ៨៧ ព្រះវស្សា យាងចូល ៨៨ ព្រះវស្សា ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និង មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សូមព្រះរាជវរោកាសដើម្បីក្រាបបង្គំទូលថ្វាយនូវព្រះពរជ័យវរថ្លៃថ្លាមហាប្រសើរ ជាមួយមនោសញ្ចេតនាគោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុត ចំពោះ **~~ព្រះករុណាថ្លៃវិសេស~~** ។ សូម **ព្រះករុណាថ្លៃវិសេស** ទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌ ព្រះជន្មាយុយឺនយូរ សុភមង្គល និងមហាជោគជ័យជានិច្ចនិរន្តរ៍ ក្នុងការបន្តព្រះរាជបេសកកម្មជាតិជាប្រវត្តិសាស្ត្រដ៏ឧត្តុង្គឧត្តមរបស់ព្រះអង្គ ក្នុងឋានៈជាព្រះបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ដើម្បីគួនចៅ ចៅទួតព្រះអង្គ នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា បន្តក្រេបជញ្ជក់នូវសេចក្ដីសុខក្សេមក្សាន្ត និងវិបុលភាព ក្រោមម្លប់ដ៏ត្រជាក់ត្រជុំរបស់ព្រះអង្គ ហើយព្រះរាជាណាចក្រកម្ពុជាកាន់តែមានកិត្យានុភាពរុងរឿងឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ។

ក្នុងឱកាសដ៏មហាប្រសើរនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមថ្លែងជាថ្មីម្តងទៀតនូវកតវេទិតា និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត និង ស្មារតីភក្ដីដ៏ស្មោះស្ម័គ្របំផុតថ្វាយចំពោះ **ព្រះករុណាថ្លៃវិសេស** ដែលព្រះអង្គទ្រង់សម្រេចបាននូវស្នាព្រះហស្ថអមតៈជាប្រវត្តិសាស្ត្រជាច្រើន មានព្រះរាជបូជនីយកិច្ចប្រកបដោយជោគជ័យដ៏ត្រចះត្រចង់នាំមកនូវឯករាជ្យជូនប្រជាជាតិ នាថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៥៣ សមិទ្ធិផលដ៏ស្ដីមស្ដែក្នុងសម័យដ៏រុងរឿងនៃ **សង្គមរាស្ត្រនិយម** ដែលបានញ៉ាំងឱ្យព្រះរាជាណាចក្រកម្ពុជាមានភាពថ្កុំថ្កើងឡើងវិញដូចសម័យ **មហានគរ** និង ជោគជ័យនៃព្រះរាជកិច្ចដឹកនាំ ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងឯកភាពជាតិ ទាំងក្នុងយុគសម័យទី ១ ទាំងក្នុងយុគសម័យ ទី ២ ក្រោយឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា ។

ឆ្លើយតបនឹងព្រះមហាករុណាទិយគុណដ៏សែនធំធេងនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាសូមប្ដេជ្ញាចិត្តមិនខ្លាចនឿយហត់ និងដោយប្រកាន់ខ្ជាប់ជានិច្ចនូវសីលធម៌ស្អាតស្អំ អភិបាលកិច្ចល្អ ដង្ហែរតាមព្រះរាជកិច្ច និង ព្រះរាជតម្រិះដ៏ឧត្តុង្គឧត្តម វិសេសវិសាលរបស់ **ព្រះករុណាថ្លៃវិសេស** ក្នុងការអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជា សម្រាប់វិបុលសុខ សុខុមាលភាពរបស់ប្រជាជនកម្ពុជា និងកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា ។

ឆ្លៀតក្នុងឱកាសនេះ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា ក៏សូមព្រះបរមរាជានុញ្ញាតថ្វាយផងដែរ នូវអភិវន្ទនកិច្ច និង ពរសព្ទសាធុការមហាប្រសើរ ចំពោះ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ។

ចំពោះទូលព្រះបង្គំជាខ្ញុំ **គាត ឈន់** ផ្ទាល់ ទូលព្រះបង្គំសូមព្រះរាជានុញ្ញាតសម្តែងសាជាថ្មីនូវកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះព្រះរាជហឫទ័យប្រោសប្រណីរបស់ **ព្រះករុណា ព្រះមហាវីរក្សត្រ** និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល** ដែលព្រះអង្គទ្រង់ចំណាយព្រះកាយពល និងពេលវេលាដ៏កម្រ ព្រះរាជានុញ្ញាតឱ្យទូលព្រះបង្គំជាខ្ញុំ បានចូលក្រាបបង្គំគាល់នៅសៀមរាបអង្គរ ក្នុងព្រះរាជដំណាក់ពោរពេញទៅដោយប្រវត្តិសាស្ត្រ ព្រមទាំងប្រោសប្រណីឱ្យបានដង្វែរទទួលព្រះរាជទានសាយភោជន៍ ជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** នាថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩ កន្លងទៅ ។ បុព្វសិទ្ធិដ៏កម្រ និងមហាកិត្តិយសនេះ នាំឱ្យទូលព្រះបង្គំជាខ្ញុំ នឹកឃើញនូវព្រះមហាករុណាទិយគុណសណ្តោសប្រណីរាប់មិនអស់របស់ **ព្រះករុណាថ្លៃវិសេស** ចំពោះទូលព្រះបង្គំជាខ្ញុំ និងខ្ញុំស្រី **ឡាយ នារី** ។

ជាទីបញ្ចប់ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា ព្រមទាំងខ្ញុំស្រី **ឡាយ នារី** សូមព្រះរាជានុញ្ញាតថ្វាយនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុត ចំពោះ **ព្រះករុណាថ្លៃវិសេស សម្តេចឪ និង ព្រះមហាក្សត្រី សម្តេចម៉ែ** ជាទីសក្ការៈ ជាមួយមនោសញ្ចេតនាគោរពស្រឡាញ់យ៉ាងជ្រាលជ្រៅបំផុត និងភក្តីភាពឥតងាករេ ។

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**គាត ឈន់**